## ៣-៣- នមស្សការ ថ្វាយបង្គំ ព្រះសង្ឃ

**-សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មាន ព្រះភាគ លោកប្រតិបត្តិហើយ ដោយប្រពៃគឺប្រតិបត្តិតាមគន្លង ព្រះនព្វលោកុត្តរធម៌,

**-ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា,

**-ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មាន ព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្សេម ចាកទុក្ខទាំងពួង,

**-សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិ គួរដល់សីល សមាធិ បញ្ញា,

**-យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណាបើរាប់ជាគូនៃបុរសទាំងឡាយមាន ៤គូគឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គនិងសោតាបត្តិផល ជាគូ ១, សកទាគាមិមគ្គ និងសកទាគាមិផល ជាគូ ១, អនាគាមិមគ្គនិង អនាគាមិផល ជាគូ១, អរហត្តមគ្គ និង អរហត្តផល ជាគូ១,

**-អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន៨គឺ ព្រះសង្ឃដែលបាន សម្រេចនូវ សោតាបត្តិមគ្គ១,សោតាបត្តិផល១, សកទាគាមិមគ្គ១,សកទាគាមិផល១, អនាគាមិមគ្គ១,អនាគាមិផល១, អរហត្តមគ្គ១,អរហត្តផល១,

**-ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនុ៎ះជាសង្ឃសាវក នៃព្រះដ៏មាន ព្រះភាគ,

**-អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យដែល បុគ្គលឧទ្ទិសចំពោះអ្នក មានសីល ហើយនាំមកអំពីចម្ងាយ បង្អោនចូល មកបូជា,

**-អាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទានគឺទានដែលបុគ្គលតាក់តែង ដើម្បីញាតិនិងមិត្រដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា,

**-ទក្ខិណេយ្យោ** លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា,

**-អញ្ជលិករណីយោ** លោកគួរដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ,

**-អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដ៏ទៃក្រៃលែងជាងគ្មាន,

**-តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណមានគុណថា សុបដិបន្នោជាដើមនោះ ដោយសិរសាគឺត្បូង,

**-តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណាសូមបូជាចំពោះនូវ ព្រះសង្ឃជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ។

(ក្រាបថ្វាយបង្គំម្តង)

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ " ← " ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។